ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៦៧

ចុះថ្ងៃទី១៨ខែកញ្ញាឆ្នាំ១៩៩៨

សាលដីកា

លេខ : ៣៩

ចុះថ្ងៃទី២៣ខែមេសាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ២៣ ខែ មេសា- ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :-

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឌិត | មុន្ទី | ជាប្រធាន |
| ២-លោក | ប៉ែន | និន | ជាចៅក្រម |
| ៣-លោក | វេវៀល | មួន | ជាចៅក្រម |
| ៤-លោក | ជីវ | កេង | ជាចៅក្រម |
| ៥-លោក | យស់ | សុខឿន | ជាចៅក្រមរក្សាការណ៍ |

ក្រឡាបញ្ជី

អ្នកស្រី យុត សុគន្ធា

តំណាងមហាអយ្យការ

លោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ២៦៤ ចុះថ្ងៃទី ០២-៦-៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១៨ ចុះថ្ងៃទី ២៣-០២-៩៨ របស់ សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ អ៊ុំ សារឹម ភេទ ស្រី អាយុ ៤៣ ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅផ្ទះលេខ ៤៣អឺ០ហិរ្ត ក្រុម ៦៣ ផ្លូវ ៥១ សង្កាត់ផ្សារថ្មី៣ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ព អ៊ុំ "ស" ម្តាយឈ្មោះ សួស នូវ "ស" , ប្តីឈ្មោះ-ខែន ណារ៉េត ផ្ទេរសិទ្ធិអោយកូនឈ្មោះ ខែន សុភារី ។មានមេធាវីលោក សួរ អ៊ឹន ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ព្រាំ រ៉ានី ភេទស្រី អាយុ ៣២ ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅផ្ទះលេខ ៦៤អឺ០ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ឃី ច្រាវីន "ស" , ម្តាយឈ្មោះ ព្រាំ មុំន "ស" ប្តីឈ្មោះ តាន់ គៀត ។



៣៧.

តាមបណ្តឹងសាទុក្ខលេខ ២៤៣ ចុះថ្ងៃទី ២៣-៦-៨៨ របស់អ្នកស្រី អ៊ុ សារីម ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ២៦៤ ចុះថ្ងៃទី ០២-៦-៨៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៦៧ ចុះថ្ងៃទី១៨-៤-៨៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៥-៤-៨៧ របស់ដើមចោទឈ្មោះ ព្រំ រ៉ានី បានបញ្ជាក់ថា កាលពីថ្ងៃទី ០១-០១-៨៦ ខ្លួនបានទិញផ្ទះលេខ ៤៧អឺ០ហ៊ិរត ពីឈ្មោះ អ៊ុ សារីម និងប្តីឈ្មោះ វ៉ែន ណារ៉េត ក្នុងតម្លៃ ១.២០០ដុល្លាអាមេរិក ពេលទិញនោះមានកិច្ចសន្យាត្រឹមត្រូវ ហើយអ្នកទាំងពីរបានធ្វើកិច្ចសន្យាជួលម្នាក់នៅបន្តទៀតក្នុងតម្លៃ ១០៥ដុល្លាអាមេរិកក្នុង ១ខែ តែរហូតមកដល់ពេលនេះអ្នកទាំងពីរពុំបានបង់ប្រាក់ថ្លៃឈ្នួលផ្ទះមកអោយខ្លួនរយៈពេល ១៦ខែ មានចំនួន ១.៦៨០ដុល្លាអាមេរិក ។

ចុងចម្លើយឈ្មោះ អ៊ុ សារីម បានឆ្លើយថា ខ្លួនពុំបានលក់ផ្ទះលេខ ៤៧ អឺ០ហ៊ិរត ផ្លូវ ៥១ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ទៅអោយឈ្មោះ ព្រំ រ៉ានី និង ពុំបានជួលផ្ទះនេះបន្តទៀតទេ ខ្លួនបានខ្ចីប្រាក់ពីឈ្មោះ ព្រំ រ៉ានី ហើយបានដាក់ប័ណ្ណផ្ទះរបស់ខ្លួនទៅអោយឈ្មោះ ព្រំ រ៉ានី ។

បានឃើញសាលក្រមលេខ១៥៥ "ក" ចុះថ្ងៃទី១២-១១-៨៧ របស់តុលាការក្រុងភ្នំពេញ ដែលមានសេចក្តីសំរេចដូចតទៅៈ-

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៥-៤-៨៧ របស់ដើមចោទឈ្មោះ ព្រំ រ៉ានី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទទួលលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០១-៥-៨៦ និង កិច្ចសន្យាជួលផ្ទះចុះថ្ងៃទី០១-៥-៨៦ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- បង្គាប់អោយឈ្មោះ អ៊ុ សារីម និង ប្តីឈ្មោះ វ៉ែន ណារ៉េត ប្រគល់ផ្ទះលេខ-៤៧ អឺ០ហ៊ិរត ក្រុម៦៣ ផ្លូវ ៥១ សង្កាត់ផ្សារថ្មីទី ៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ អោយទៅឈ្មោះ ព្រំ រ៉ានី និង អោយថ្លៃឈ្នួលផ្ទះចំនួន ១.៦៨០ដុល្លាអាមេរិករយៈពេល ១៦ខែ គិតពីថ្ងៃទី ០១-៥-៨៦ ទៅពេលដែលសាលក្រមនេះចូលជាស្ថាពរ ។

៤-សំរេចដាក់គុកបង្ខំរូបកាយឈ្មោះ អ៊ុ សារីម និង ប្តីឈ្មោះ វ៉ែន ណារ៉េត ចំនួន ៨ខែ ក្នុងម្នាក់ៗ កាលបើឈ្មោះខាងលើមិនព្រមបង់ប្រាក់អោយឈ្មោះ ព្រំ រ៉ានី តាមមាត្រា ១៣៣ នៃច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-បង្គាប់អោយឈ្មោះ អ៊ុ សារីម និង វ៉ែន ណារ៉េត បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធតែម ១.៨០០រ៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ៛០០ រង្វាន់សាក្សី ២.០០០រ៛០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៣.០០០រ៛០០ សរុប ៧.០០០រ៛០០ ដែលដើមចោទបានបង់រួចជាស្រេច កាលបើចូលឧទ្ធរណ៍ បង្គាប់អោយលោក អ៊ុ សារីម និង វ៉ែន ណារ៉េត សងប្រាក់ ៧.០០០រ៛០០ អោយទៅដើមចោទវិញ ។ និង បង្គាប់អោយបង់ពន្ធសមាមាត្រ ចំនួន ១ភាគរយលើប្រាក់សរុប ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន ៨០ ភាគរយ ២០ភាគរយ



៧.

ទៀតជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៦_ សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគី សំរេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

សាលក្រមនេះត្រូវបានឈ្មោះ អ៊ុំ សារីម ប្តឹងឧទ្ធរណ៍តាមបណ្តឹងចុះថ្ងៃទី ២៨-១២-៨៧ ស្នើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីកាលេខ ២៦៤ ចុះថ្ងៃទី ០២-៦-៨៨របស់ សាលាឧទ្ធរណ៍ ដែលសំរេចដូចតទៅ :-

១_ ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៨-១២-៨៧ របស់ឈ្មោះ អ៊ុំ សារីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹង គតិច្បាប់ ។

២_ តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៤៥ "ក" ចុះថ្ងៃទី ១២-១១-៨៧- របស់ តុលាការក្រុងភ្នំពេញ ទុកជាបានការដដែលដោយគ្រាន់តែកែប្រែចំនួនថ្លៃឈ្នួលផ្ទះ ក្នុងចំណុចទី៣ នៃសេចក្តីសំរេចពី ១.២៨០ទៅ ៨០០ដុល្លារវិញ ។ ចំណុចក្រៅពីនេះតម្កល់ទុកជាបានការដដែល ។

៣_ កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រ៛០០ ដែលដើមបណ្តឹងបានបង់រួចហើយគឺពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ុនចំនួន២៥៥០រ៛ រង្វាន់ក្រឡាបញ្ជីការទីប្រាក់៤៥០រ៛ ចំណាយលើដីកាការៈចំនួន៥.០០០រ៛ និង រង្វាន់រាជ្ញាររតុលាការចំនួន ៥.០០០រ៛០០ ។

៤_សាលដីកានេះធ្វើឡើងជាសាធារណៈនៅថ្ងៃទី២៥-៥-៨៨ចំពោះមុខគូក្តីនិងប្រកាសជាសាធារណៈនៅថ្ងៃទី២-៦-៨៨ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១២៤៣ចុះថ្ងៃទី១៣-៦-៨៨ របស់អ្នកស្រីអ៊ុំ សារីម ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី១២-១០-៨៨របស់អ្នកស្រី អ៊ុំ សារីម

បានឃើញសារណាតបរបស់ អ្នកស្រី ព្រំ រ៉ានី ចុះថ្ងៃទី១៥-១១-៨៨

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: -សាលដីកាសាលាឧទ្ធរណ៍ដែលសំរេចសេចក្តី មកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះកែន សុភារី ដែលបានឆ្លើយនៅពេលសវនាការថា-:- ផ្ទះនេះជាផ្ទះរបស់ខ្លួន ម្តាយខ្លួន ខ្ចីលុយគាត់ចំនួន ១.០០០ដុល្លារអាមេរិក ដោយដាក់បណ្ណគ្រួសារ ។ ឪពុកខ្លួនពុំបានដឹងរឿងនេះទេ លិខិតទាំងបីនេះ ជាលិខិតក្លែងបន្លំ ព្រោះម្តាយខ្លួនអត់ចេះអក្សរ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ព្រំ រ៉ានី ដែលបានឆ្លើយនៅពេលសវនាការ ថា :- ពេលធ្វើលិខិតផ្ទេរនោះ គឺធ្វើនៅមុខរដ្ឋអំណាច ហើយពេល ២ ៣ ថ្ងៃក្រោយ

មកប្តីគាត់ក៏មកផ្តិតមេដៃអោយទៀត ។ សុំលោកប្រធានជួយអោយគាត់គោរពកិច្ចសន្យា និង សងថ្លៃឈ្នួលផ្ទះគ្រប់ចំនួន ។

លោក ឈួ អ៊ុន មេធាវីរបស់ចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា:-
តាមចម្លើយរបស់នាងកែន សុភារី ថា ពេលខ្ចីប្រាក់នោះ នាងគ្មានល្ងោះដួន ចិត្ត បានអានកិច្ចសន្យាអោយស្តាប់ថា អ៊ុំ សារីម ខ្ចីប្រាក់ចំនួន ១.០០០ ដុល្លា ដោយមានការប្រាក់ ១០ ដុល្លា ក្នុងមួយខែ តែបើគ្មានការប្រាក់រយៈពេល ៣ខែ គឺត្រូវរឹបអូសយកផ្ទះ តែលិខិតនេះបាត់ បែរជាលេចលិខិត៣ប្រភេទផ្សេងទៀតគឺ:-

-កិច្ចសន្យាលក់

-កិច្ចសន្យាជួល

-កិច្ចសន្យាផ្ទេរផ្ទះមកវិញ

ហើយដែលលិខិតទាំងបីនេះ ចុះថ្ងៃ ខែ ឆ្នាំ តែមួយ ។

កន្លែងទិញផ្ទះ ឧបមាថាភាគី អ៊ុំ សារីម លក់មែនគឺវាមិនសមស្របព្រោះ ១.០០០ដុល្លាទិញផ្ទះដែលមានទំហំ ៦គុណ ៥ ៥ នៅប្លុកក្រោយសារមន្ទីរគងទឹក គឺវាថោកពេកព្រោះផ្ទះនោះគេធ្លាប់អោយថ្លៃដល់ទៅ៦ទៅ៧ពាន់ដុល្លាឯណោះ តែគាត់មិនលក់ ។

ក្នុងនាមមេធាវី លោកសុំបដិសេធកិច្ចសន្យាទាំងបីនេះព្រោះកិច្ចសន្យានេះជាការឆបោកបញ្ឆោត ក្លែងបន្លំ អានអោយស្តាប់ថាខ្ចី ដល់លិខិតយកមកអោយផ្សេងដើម្បី គ្នាមិនចេះអក្សរ ត្រឹក្រ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី អ៊ុំ សារីម ដែលបានឆ្លើយនៅពេលសវនាការថា: ខ្លួនផ្តិតមេដៃអោយតែពាក្យបី ៖ ដូចដែលកូនខ្លួនបានឆ្លើយរួចហើយ ។ ហើយ ព្រំវានី បាននិយាយថាកុំអោយពិបាករាប់មួយថ្ងៃមួយម៉ឺនក៏បានដែរ ។

លោក អ៊ុក វ៉ាន់ដេត មេធាវីដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថា :-
បើគាត់ដឹងថាលិខិតនេះមិនមែនជាលិខិតខ្ចីប្រាក់ ហេតុអីគាត់មិនប្តឹង កន្លែងផ្ទះសមស្របហើយនៅប្លុកអនាធិបតេយ្យដែលមានផ្ទះតូចចង្អៀត និង គ្មានផ្លូវចេញ-ចូល ត្រឹមត្រូវ លោកសុំអោយតុលាការតម្កល់សាលក្រម និង សាលដីកា តុលាការថ្នាក់ក្រោម ។

លោក ឈួ អ៊ុន បានសន្និដ្ឋានបន្តទៀតថា :-

កិច្ចសន្យានេះមិនអាចធ្វើទៅបានទេ ព្រោះ ផ្តិតមេដៃតែម្នាក់ គ្មានការព្រមព្រៀងពីប្តី ។ ចំពោះតម្លៃគឺមិនអាចទៅរួចទេក្នុងតម្លៃ ១.០០០ ដុល្លា ចំពោះបញ្ហាប្រាក់ដែលបានសងហើយ ភាគីសងមានឯកសារ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវី នៃ គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៤៣ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់អ្នកស្រី អ៊ី សារ៉ែម ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ កែខ្លួចតុលាការក្រុងភ្នំពេញដែរ ដែលសំរេចទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និង កិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី០១ ខែ ៥ ឆ្នាំ ១៩៩២ ហើយបង្គាប់អោយអ្នកស្រី អ៊ី សារ៉ែម ប្រគល់ផ្ទះលេខ ៤៧ អឺ០ហ្វ៊ិត និង សងឈ្នួលផ្ទះ ចំនួន ១.២៨០ ដុល្លាអាមេរិក ទៅអ្នកស្រី ព្រំ រ៉ានី នោះជាការភ័ន្តច្រឡំ ពីព្រោះថា :-

. កិច្ចសន្យា និង លិខិតនេះផ្ទុយច្បាប់ជាចម្បង ហើយមានដោយវៀចពីគ្នា ដែលមួយមានការយល់ព្រមពីស្វាមីអ្នកស្រី អ៊ី សារ៉ែម និងមួយទៀតពុំមានស្នាមមេដៃយល់ព្រមពីស្វាមីអ្នកស្រី អ៊ី សារ៉ែម ទេ ដែលជាកាលការណ៍ គប្បីតុលាការអង្គសេចក្តីធ្វើការស៊ើបអង្កេតអោយបានច្បាស់លាស់។

. ករណីលក់ផ្ទះលេខ ៤៧អឺ០ហ្វ៊ិត នេះមានករណីទាបពេក ដែលតុលាការគប្បីពិចារណាពីសុពលភាព នៃ លិខិតទាំងពីរនេះ តាមមាត្រា ១១ ១២ នៃ ក្រឹត្យ-ច្បាប់លេខ ៣៨ក្រ-ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់ សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ២៤៣ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់អ្នកស្រី - អ៊ី សារ៉ែម ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ២៦៤ ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ១៩៩៨ របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣- បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១៦៧ ចុះថ្ងៃទី ១៨-៩-១៩៩៨ របស់ តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛០០ ដែលអ្នកស្រី ព្រំ រ៉ានី បង់ជំនួសរួចហើយ

គឺ :-

- ពន្ធចុះបញ្ជាក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន-៨០០៛០០ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៣ ខែ មេសា-ឆ្នាំ ១៩៩៨ ។